មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

ភ្នំពេញ ថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ២០១៤

## ម.ស.ម.ក សម្ពោធយុទ្ធនាការអំពាវនាវឲ្យប្រជាពលរដ្ឋចូលរួមប្រយុទ្ធប្រឆាំងនិទណ្ឌភាព

នៅថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ២០១៤ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សម្ពោធយុទ្ធនាការបញ្ចប់និទណ្ឌភាពប្រចាំឆ្នាំក្នុងឱកាសទិវាបញ្ចប់និទណ្ឌភាពអន្តរជាតិសម្រាប់បទល្មើសប្រឆាំងលើអ្នកសារព័ត៌មាន ដែលអង្គការសហប្រជាជាតិទទួលស្គាល់ជាលើកដំបូង។ ម.ស.ម.ក ឆ្លៀតក្នុងឱកាសនេះ សូមលើកនូវបញ្ហានិទណ្ឌភាពដែលរីករាលដាលយ៉ាងខ្លាំងនៅកម្ពុជា។ យុទ្ធនាការនេះ មានគោលបំណងប្រមូលគៀងគរ និងផ្សាយបន្តនូវការទាមទាររបស់សាធារណជនទៅកាន់រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) ដើម្បីបញ្ចប់និទណ្ឌភាព។ យើងសូមអំពាវនាវដល់ប្រជាពលរដ្ឋឲ្យថតរូបខ្លួនឯងផ្ទាល់កាន់បដាដែលមានន័យក្នុងការប្តេជ្ញាប្រឆាំងនិទណ្ឌភាព។ ម.ស.ម.ក នឹងប្រមូលរូបថតទាំងនោះរយៈពេលមួយខែពេញ គឺអំឡុងខែវិច្ឆិកា និងដាក់បញ្ចូលរូបទាំងនោះទៅក្នុងផ្ទាំងបដាដ៏ធំមួយ។ នៅថ្ងៃទី ២ ខែធ្នូ ម.ស.ម.ក នឹងបញ្ជូនផ្ទាំងបដានេះទៅ ក្រសួងយុត្តិធម៌ដើម្បីបង្ហាញពីការទាមទាររបស់សាធារណជនក្នុងការបញ្ចប់និទណ្ឌភាព។ ដើម្បីស្វែងយល់អំពីរបៀបដែលអ្នកអាចថតរូប និងផ្ញើមក ម.ស.ម.ក សូមមើល ៖ http://www.cchrcambodia.org/Impunity2014

និទណ្ឌភាព មានន័យថា "ការមិនត្រូវបានផ្តន្ទាទោស" ឬ "គ្មានផលវិបាកណាមួយ"។ ជនប្រព្រឹត្តបទល្មើសតែងតែមិនត្រូវបានផ្តន្ទាទោសចំពោះអំពើដែលខ្លួនប្រព្រឹត្ត ហើយជនរងគ្រោះមិនដែលទទួលបានយុត្តិធម៌នោះទេ។ ដោយសារតែ កង្វះឆន្ទៈក្នុងការផ្តន្ទាទោសលើជនប្រព្រឹត្តបទល្មើសទាំងនោះ បានធ្វើឲ្យបទល្មើសទាំងនោះតែងតែមិនត្រូវបានស៊ើបអង្កេតឲ្យត្រឹមត្រូវ និងឯករាជ្យ ឬសំណងសមរម្យសម្រាប់ជនរងគ្រោះនោះដែរ។ វប្បធម៌និទណ្ឌភាពបានគំរាមកំហែងលើសិទ្ធិទទួលបានការពិត យុត្តិធម៌ និងសំណងត្រឹមត្រូវ ហើយបង្កឲ្យមានភាពភ័យខ្លាចក្នុងការអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិ និងសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី។ ចំណុចនេះកាន់តែធ្វើឲ្យអន្តរាយដល់ការរីកចម្រើននៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

បញ្ហានិទណ្ឌភាពក្នុងប្រទេសកម្ពុជាបានកើតឡើងក្នុងទម្រង់អំពើឃាតកម្មលើសកម្មជនសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន ដែលបទល្មើសទាំងនោះមិនត្រូវបានស៊ើបអង្កេតឡើយ និងករណីដែលកងកម្លាំងសន្តិសុខបានប្រើប្រាស់កម្លាំងហួសហេតុមកលើបាតុករក៏មិនត្រូវបានដាក់ទណ្ឌកម្ម ហើយទង្វើប្រព្រឹត្តល្មើសរបស់មន្ត្រីដែលមានទំនាក់ទំនងល្អជាមួយអ្នកកាន់អំណាចក៏មិនត្រូវបានយកមកផ្តន្ទាទោសដែរ។ ចាប់តាំងពី ខែកញ្ញា ឆ្នាំ២០១៣មក យ៉ាងហោចណាស់មានប្រជាពលរដ្ឋចំនួន ៦ នាក់ ត្រូវកងកម្លាំងសន្តិសុខបាញ់សម្លាប់ ក្នុងអំឡុងពេលដែលពួកគេធ្វើការតវ៉ា មានមួយចំនួនទៀតរង

របួស និងម្នាក់បាត់ខ្លួន។ ករណីទាំងអស់នេះ រដ្ឋាភិបាលមិនបានចាត់វិធានការស៊ើបអង្កេតឲ្យបានត្រឹមត្រូវណាមួយឡើយ។

**អ្នកស្រី ចក់ សុភាព នាយិកាប្រតិបត្តិរបស់ ម.ស.ម.ក មានប្រសាសន៍ថា ៖**

*"និទណ្ឌភាពបានរំលោភលើសិទ្ធិមនុស្សជាមូលដ្ឋាន និងធ្វើឲ្យអន្តរាយដល់នីតិរដ្ឋ និងគោលការណ៍មូលដ្ឋានរបស់លទ្ធិប្រជាធិបតេយ្យ។ ប្រការទាំងនេះនាំមិនមែនប៉ះពាល់ដល់ជនរងគ្រោះតែម្យ៉ាងនោះទេ ប៉ុន្តែក៏ធ្វើឲ្យប៉ះពាល់ដល់សង្គមទាំងមូល ។ ពេលនេះប្រជាពលរដ្ឋកម្ពុជាគួរតែចូលរួមទាំងអស់គ្នា ក្នុងការទាមទារឲ្យនាំយកបុគ្គលដែលប្រព្រឹត្តនូវអំពើអយុត្តិធម៌ទាំងនោះទៅទទួលខុសត្រូវចំពោះមុខច្បាប់។ ដូច្នេះ ខ្ញុំសុំឲ្យប្រជាពលរដ្ឋចូលរួមក្នុងការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពនេះ។"*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង អ្នកស្រី ចក់ សុភាព នាយិកាប្រតិបត្តិនៃ ម.ស.ម.ក តាមទូរសព្ទ +(៨៥៥) ១១ ៩៤៣ ២១៣ ឬអ៊ីមែល** chaksopheap@cchrcambodia.org **ឬទាក់ទងកញ្ញា សន រ៉ាមណា អ្នកសម្របសម្រួលគម្រោងសេរីភាពបញ្ចេញមតិ តាមទូរសព្ទ +(៨៥៥)១៧ ៦៥៥ ៥៥១ ឬ អ៊ីមែល** ramanasorn@cchrcambodia.org

**បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ទនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្តាញសាកលសម្រាប់សេរីភាពបញ្ចេញមតិ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងនឹងការធ្វើទារុណកម្មពិភពលោក (OMCT) បណ្តាញទារុណកម្ម អែស អូ អែស។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងបានទទួលពានរង្វាន់ទំនាក់ទំនងដើម្បីការផ្លាស់ប្តូរសង្គម ផ្តល់ដោយ មជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យ ឃ្វីនស្លែន ក្នុងទីក្រុងប្រ៊ីសប៊េន ប្រទេសអូស្ត្រាលី។